អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
Victims Support Section
Section d'appui aux victimes

ភ្នំពេញ ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អង្គភាពគាំពារជនរងគ្រោះនឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី២ ឆ្នាំ២០១២ នៅក្រុងស្ទឹងសែន ខេត្តកំពង់ធំ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី២ ក្នុងឆ្នាំ២០១២នេះ នៅខេត្តកំពង់ធំ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ២០០ នាក់ នៃសំណុំរឿង ០០២។ វេទិកាថ្នាក់តំបន់នេះនឹងប្រព្រឹត្តទៅនៅបន្ទប់ប្រជុំសាលាខេត្តកំពង់ធំ ***នាថ្ងៃអង្គារ៍ ទី៨ ខែឧសភា ឆ្នាំ២០១២ ពីម៉ោង៩:០០ព្រឹក ដល់ ម៉ោង៥:០០ រសៀល***។ *(អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវរក្សាជាសម្ងាត់)*។

វេទិកាថ្នាក់តំបន់នេះមានគោលបំណងផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនូវ៖

១) ព័ត៌មានជុំវិញការវិវឌ្ឍថ្មីៗនៃសំណុំរឿង ០០២ ដែលកំពុងដំណើរការជំនុំជម្រះក្តី

២) ស្តាប់ការពន្យល់ពីមេធាវីរបស់ខ្លួន អំពីការបំបែកនីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿង០០២

៣) មានឱកាសយល់ដឹងពីសិទ្ធិរបស់ខ្លួនក្នុងនីតិវិធីតុលាការនៃសំណុំរឿង ០០២

៤) ស្វែងយល់អំពីដំណាក់កាលដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងគ្រោះដោយឧក្រិដ្ឋកម្មផ្សេងៗគ្នា ដែលត្រូវបញ្ចូលក្នុងដំណើរការជំនុំជម្រះក្តីជាផ្នែកៗដាច់ពីគ្នា។

ដើមបណ្តឹងរដ្ឋប្បវេណីទាំង ២០០នាក់ មកពីខេត្តកំពង់ធំ សៀមរាប និងព្រះវិហារ និងស្ថិតក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំង ៣ ៨៦៤ នាក់ និងដែលមិនធ្លាប់បានចូលរួមតាមដានសវនាការសំណុំរឿង០០២នៅឡើយ។

អង្គភាពគាំពារជនរងគ្រោះមានគម្រោងរៀបចំវេទិកាថ្នាក់តំបន់ចំនួន ៨ ក្នុងឆ្នាំ២០១២-២០១៣ ក្នុងទិសដៅ "អត្ថន័យនៃការចូលរួមរបស់ជនរងគ្រោះក្នុងដំណើការនីតិវិធី អ.វ.ត.ក" ហើយរវាងឆ្នាំ ២០០៩ - ២០១១ វេទិកាថ្នាក់តំបន់ចំនួន១៥ ត្រូវបានរៀបចំធ្វើរួចមកហើយ។

---

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖
អ៊ឹម សុភា, ប្រធានកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ
ទូរស័ព្ទចល័ត: ០៧៧ ៧៧៧ ៣៦៧, អ៊ីម៉ែល: im.sophea@eccc.gov.kh